**សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន**

លេខ ១០៧/១៥ ណ.ស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥

**<u>សូមគោរពជូន</u>**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)**

**<u>កម្មវត្ថុ:</u>** សំណើសុំការអនុញ្ញាតឲ្យក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ បង់ប្រាក់សមាជិកភាព និង អនុញ្ញាតឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ កែសម្រួលរូបមន្តនៃការបង់ប្រាក់សមាជិកភាព ជូនសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅតាមរាជធានី ខេត្ត និង សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

**<u>យោង:</u>**
- លិខិតលេខ ០៥៤ សជណ/គ.ជ.វ.វ ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០០៧ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- លិខិតលេខ ២០១៧ សជណ ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ ស្តីពីការទទួលស្គាល់ប្រធាន និងសមាសភាពថ្មីនៃរចនាសម្ព័ន្ធ ព្រមទាំងធ្វើវិសោធនកម្មលក្ខន្តិកៈ និងប្តូរឈ្មោះពីសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ទៅជាសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា
- ស្មារតីនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិជាតិ នៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន នៅថ្ងៃទី ២៦-២៧ ខែតុលា នៅខេត្តក្រចេះ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូនសម្តេចមេត្តាជ្រាបថា ផ្អែកតាមលិខិតរបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការលេខ ០៥៤ សជណ/គ.ជ.វ.វ ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០០៧ ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាសមាជិកសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមរាជធានី ខេត្ត បានបង់ប្រាក់សមាជិកភាពប្រចាំឆ្នាំចំនួន ៣០០.០០០ (បីរយពាន់) រៀល មកសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមរាជធានី ខេត្ត ហើយសមាគមទាំងនេះ បានផ្ទេរប្រាក់សមាជិកភាព ចំនួន ១៥% ឬ ៤៥.០០០ រៀល មកសម្ព័ន្ធភាពជាតិឃុំ សង្កាត់។ តាមរយៈការផ្ទេរថវិកានេះ សម្ព័ន្ធភាពជាតិឃុំ សង្កាត់ បានទទួលចំណូលពីប្រាក់សមាជិកភាពចំនួន ៧៣.៤៨៥.០០០ រៀល ឬ ១៨,៣៧១ ដុល្លារអាមេរិក ជារៀងរាល់ឆ្នាំ។

ជាមួយនឹងថវិកាជាប្រាក់សមាជិកភាពចំនួន ៣០០.០០០ រៀល ក្នុងមួយឆ្នាំដែលក្រុមប្រឹក្សាឃុំ សង្កាត់ បានបង់មកសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមរាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិឃុំ សង្កាត់ សមាគម និងសម្ព័ន្ធភាពជាតិ មានលទ្ធភាពអនុវត្តសកម្មភាពខ្លះៗរបស់

ខ្លួន ដូចជាការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាសមាគម កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិសមាគម កិច្ចប្រជុំថ្នាក់ដឹកនាំសមាគម និងការរៀបចំវេទិការបស់សមាគមនៅថ្នាក់ក្រុង ស្រុក និងការពិគ្រោះយោបល់លើកិច្ចការផ្សេងៗ ដើម្បីជាប្រយោជន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់។

នៅក្នុងអំឡុងឆ្នាំ២០១៣ និងឆ្នាំ២០១៤ សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមរាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិឃុំ សង្កាត់ បានពង្រីកសមាជិកភាពរបស់ខ្លួន ដោយមានបញ្ចូលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មកក្នុងស្ថាប័នរបស់ខ្លួន ហើយបានក្លាយទៅជាសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅតាមរាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា។ ប្រការនេះ មានន័យថា ទាំងសមាគមនៅតាមរាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិ លែងបំរើឲ្យសមាជិករបស់ខ្លួន ត្រឹមតែថ្នាក់ឃុំ សង្កាត់ ទៀតហើយ គឺត្រូវបំរើឲ្យសមាជិកទាំងអស់នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់។

ជាមួយនឹងថវិកាដ៏តិចតួចដែលសមាគមនៅតាមរាជធានី ខេត្ត ទទួលបានពីសមាជិករបស់ខ្លួន ចំនួន ៣០០.០០០ រៀល ហើយសម្ព័ន្ធភាពជាតិ ទទួលបាន ៤.៥០០០ រៀលនោះ ការអនុវត្តសកម្មភាពរបស់សមាគម ជាពិសេសរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ពឹងផ្អែកស្ទើរតែទាំងស្រុងលើថវិកាគាំទ្រពីដៃគូអភិវឌ្ឍន៍។ ក្នុងស្ថានភាពបច្ចុប្បន្នដែលសេដ្ឋកិច្ចរបស់កម្ពុជា មានការវិវត្តដោយបានប្រែក្លាយពីប្រទេសដែលមានចំណូលតិច ទៅជាប្រទេសដែលមានចំណូលមធ្យម ធ្វើឲ្យដៃគូអភិវឌ្ឍន៍មួយចំនួន បានទាមទារឲ្យសមាគមនៅតាមរាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិ ត្រូវបង្កើនថវិកា ដើម្បីគាំទ្រការអនុវត្តសកម្មភាពរបស់ខ្លួនផ្ទាល់។ ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់ នៅតែបន្តបង់ប្រាក់សមាជិកភាពចំនួន ៣០០.០០០ រៀល ហើយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មិនបានរួមចំណែកបង់ប្រាក់សមាជិកភាពដល់សមាគម និងសម្ព័ន្ធភាពជាតិ ដូចនៅពេលសព្វថ្ងៃនេះ ទាំងសមាគម និងសម្ព័ន្ធភាពជាតិ នឹងជួបហានិភ័យខ្ពស់ក្នុងការបន្តនិរន្តរភាពជាស្ថាប័នតំណាងឲ្យក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយសារមិនមានថវិកាគ្រប់គ្រាន់ក្នុងការទ្រទ្រង់សកម្មភាពរបស់ខ្លួន។

ដើម្បីបញ្ចៀសហានិភ័យនេះ សមាជិកក្រុមប្រឹក្សាជាតិ នៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បានសម្រេចនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួន ដែលបានប្រព្រឹត្តទៅ <u>នៅថ្ងៃទី ២៦-២៧ ខែតុលា</u> នៅសាលមហោស្រពខេត្តក្រចេះ ដោយតម្រូវឲ្យមានការកែសម្រួលលើរូបមន្តនៃការបង់ប្រាក់សមាជិកភាពដែលមានចំនួនថេរស្មើគ្នានៅពេលសព្វថ្ងៃនេះ ទៅជាអត្រាភាគរយវិញ។ រូបមន្តថ្មីដែលសមាជិកក្រុមប្រឹក្សាជាតិនៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បានសម្រេច គឺ<u>*ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវបង់ប្រាក់សមាជិកភាពប្រចាំឆ្នាំចំនួន ៣,៥% នៃប្រាក់រដ្ឋបាលរបស់ខ្លួន ដកចេញនូវប្រាក់បៀវត្សរ៍របស់បុគ្គលិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ រីឯក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបង់ប្រាក់សមាជិកភាពប្រចាំឆ្នាំចំនួន ២,៥% នៃប្រាក់រដ្ឋបាលរបស់ខ្លួន ដកចេញនូវប្រាក់បៀវត្សរ៍របស់បុគ្គលិកក្រុមប្រឹក្សាឃុំ សង្កាត់។*</u>

ផ្អែកតាមរូបមន្តថ្មីនៃការបង់ប្រាក់សមាជិកភាពសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅតាមរាជធានី ខេត្ត នឹងទទួលបានប្រាក់សមាជិកភាពប្រចាំឆ្នាំចំនួន ១.០០៥.២៥៣.

៩៥០ (មួយពាន់ប្រាំលានពីររយហាសិបបីពាន់ប្រាំបួនរយហាសិប) រៀល ស្មើនឹង ២៥១.៣១៣ (ពីររយហាសិបមួយពាន់បីរយដប់បី) ដុល្លារអាមេរិក។ ផ្អែកតាមលក្ខន្តិកៈរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន សមាគមនៅតាមរាជធានី ខេត្ត ត្រូវផ្ទេរប្រាក់សមាជិកភាពចំនួន ២០% មកសម្ព័ន្ធភាពជាតិ ដូច្នេះ *សម្ព័ន្ធភាពជាតិ នឹងទទួលបានថវិកាពីការផ្ទេរប្រាក់សមាជិកភាពចំនួន ២០១.០៥០.៧៩០ (ពីររយមួយលានហាសិបពាន់ប្រាំពីររយកៅសិប) រៀល ស្មើនឹង ៥០.២៦៣ (ហាសិបពីររយហុកសិបបី) ដុល្លារអាមេរិក* ហើយសមាគមនៅតាមរាជធានី ខេត្ត នឹងនៅសល់ថវិកាចំនួន ៨០៤.២០៣.១៦០ (ប្រាំបីរយបួនលានពីររយបីពាន់មួយរយហុកសិប) រៀល ស្មើនឹង ២០១.០៥១ (ពីររយមួយពាន់ហាសិបមួយ) ដុល្លារអាមេរិក។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូមសម្តេច មេត្តាអនុញ្ញាតឲ្យក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ បង់ប្រាក់សមាជិកភាព និងអនុញ្ញាតឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ កែសម្រួលរូបមន្តនៃការបង់ប្រាក់សមាជិកភាពជូនសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅតាមរាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដោយក្តីអនុគ្រោះ។

ខ្ញុំបាទសូមជូនភ្ជាប់មកជាមួយនូវតារាងគណនាការបង់ប្រាក់សមាជិកភាពតាមរូបមន្តថ្មី និងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាជាតិរបស់សម្ព័ន្ធភាពក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

សូមសម្តេច មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

**ប្រធាន**

**សយ ភូរ៉ាស**

# កំណត់ហេតុកិច្ចប្រជុំ

# ក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិជាតិរបស់

# សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

# ខេត្តក្រចេះ ថ្ងៃទី ២៦-២៧ ខែតុលា ឆ្នាំ២០១៥

ឆ្នាំពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីម្ភៃប្រាំមួយ ដល់ថ្ងៃទីម្ភៃប្រាំពីរ នៅសាលមហោស្រពសាលាខេត្តក្រចេះ ក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិកាប្រតិបត្តិជាតិរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន បានរៀបចំកិច្ចប្រជុំរបស់ខ្លួនក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប។ កិច្ចប្រជុំនេះ ត្រូវរៀបចំឡើងក្នុងបំណងពង្រឹងអង្គអភិបាលកិច្ច ស្របតាមលក្ខន្តិកៈ របស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន (NLC) ពិនិត្យលទ្ធផលការងារ ឆ្នាំ២០១៥ បញ្ហាប្រឈម ដំណោះស្រាយ និងលើកទិសដៅឆ្នាំ២០១៦។ កិច្ចប្រជុំនេះឧបត្ថម្ភគាំទ្រដោយ គ.ជ.អ.ប ក្រសួងមហាផ្ទៃ និង UNDP-EU/ACES។

## ១. សមាសភាពចូលរួម

កិច្ចប្រជុំអញ្ជើញចូលរួម ពីតំណាង គ.ជ.អ.ប តំណាងក្រសួងមហាផ្ទៃ ព្រឹទ្ធសភា ប្រធានក្រុមប្រឹក្សាខេត្ត អភិបាលរង តំណាងក្រសួងបរិស្ថាន សមាជិក សមាជិការក្រុមប្រឹក្សា និងគណៈកម្មាប្រតិបត្តិជាតិ មន្ត្រីអគ្គលេខាធិការ មន្ត្រីគាំទ្រខេត្តទាំង ៦ លេខាសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ចំនួន១២៥ នាក់ ក្នុងនោះស្រីចំនួន ៣២ នាក់។ (ភ្ជាប់មកជាមួយ *ឧបសម្ព័ន្ធទី១*)

## ២. របៀបវារៈ

ក. កម្មវិធីបើក

- មតិស្វាគមន៍របស់ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តក្រចេះ
- ចំណាប់អារម្មណ៍របស់ប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន
- សុន្ទរកថាប់របស់ តំណាងក្រសួងមហាផ្ទៃ

ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដែលប្រមូលផ្តុំបានសំលេង សម្រាប់ចូលរួមក្នុងការរៀបចំគោលនយោបាយនានា របស់រាជរដ្ឋាបាលភិបាល។ ឯកឧត្តមបានគូសបញ្ជាក់ថាលក្ខណៈពិសេស របស់ ផអ៣ ដំណាក់កាលទី១ និងទី២។ សមិទ្ធផលដំណាក់កាលទី១ បានបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិមាន គឺសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និង សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងការចង្អុលទិសក្នុងការបង្កើតអគ្គលេខាធិការដ្ឋានរួមរបស់សមាគមទាំងពីរ។ អគ្គលេខាធិការដ្ឋាននេះ អ្នកជំនាញការបរទេសក៏បានបញ្ជាក់ផងដែរថា ប្រទេសជាច្រើនបង្កើតអគ្គលេខាធិការដ្ឋានដាច់ៗដោយឡែកពីគ្នា ដោយសារស្វ័យភាពរបស់សមាគមនីមួយៗ។ ប៉ុន្តែបរិបទនៅកម្ពុជា បង្កើតរួមក្នុងគោលបំណងប្រមូលផ្តុំសម្លេង ការជួយត្រួតពិនិត្យគ្នាទៅវិញទៅមក និងដោយសារធនធានយើងមានកម្រិត។ ជាការកត់សម្គាល់របស់ ឯកឧត្តមបន្ថែមថា រាល់សមិទ្ធិផលនានា សម្រេចបានរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន គឺសុទ្ធជាការរួមចំណែកធនធានហិរញ្ញវត្ថុរបស់ដៃគូនានា ដែលថវិកានេះប្រហែល ៦០% នៃថវិកាចំណាយ រួមទាំងធនធានមនុស្សផងដែរ ហើយសមាគមក៏មានការអនុគ្រោះទីតាំងធ្វើការនៅក្នុងបរិវេនព្រឹទ្ធសភា។ បទពិសោធន៍សមាគមនៅពិភពលោក ឯកឧត្តមកត់សម្គាល់ថា នៅប្រទេសឥណ្ឌូនេស៊ី សមាគមថ្នាក់ខេត្តមិនមានថវិកាគ្រប់គ្រាន់ទេ ប៉ុន្តែថ្នាក់ស្រុកគេមានថវិកាគ្រប់គ្រាន់។ នៅកម្ពុជាយើងសមាគមជួបបញ្ហាថវិកាទាំងពីរប្រភេទ។ នៅពេលមានថវិកាគ្រប់គ្រាន់ចាំយើងបំបែកជាការងាយស្រួល ជាជាងបំបែកហើយបង្រួមវិញ។ ឧទាហរណ៍ខេត្តកែប បើសិនជាយើងបង្រួមមកវិញនោះវាជាការលំបាក។ ការងារអគ្គលេខាធិការដ្ឋាននេះ យើងក៏បានជ្រើសរើស និងអនុម័តអគ្គលេខាធិការ អគ្គអគ្គលេខធិការរង បុគ្គលិកស្នូល ប្រកបដោយគណនេយ្យភាព តម្លាភាព។ នៅឱកាសដ៏ថ្លៃថ្លានេះ ឯកឧត្តម ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- ការពង្រឹងស្ថាប័ន សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ត្រូវខិតខំពង្រឹងស្ថាប័ន របស់យើងឱ្យក្លាយជាយន្តការប្រមូលផ្តុំសំលេង សម្រាប់ចូលរួមដោះស្រាយបញ្ហានានា ជាពិសេសបញ្ហាដែលជះឥទ្ធិពលដល់ក្រុមប្រឹក្សាលើការគ្រប់គ្រង ការចាត់ចែងការប្រើប្រាស់មូលនិធិ និងការអនុវត្តគម្រោងនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ខិតខំពង្រឹងស្ថាប័នដើម្បីត្រៀមខ្លួន ទទួលយកមុខងារដែលនឹងត្រូវផ្ទេរនៅដើមឆ្នាំ២០១៦ នេះ ដែលមុខងារត្រូវផ្ទេរ គឺមួយចំនួនពីថ្នាក់ខេត្ត និងមួយចំនួនពីក្រសួងនានា ពិសេសការប្រមូលសំរាម ការងារអប់រំ (មតេយ្យ, បឋមសិក្សា) ការងារសុខាភិបាល (មណ្ឌលសុខភាព)

ជាមួយនេះដែរឯកឧត្តមបានជម្រាបជូន អំពីសមិទ្ធិផល និងបញ្ហាប្រឈមឆ្នាំ២០១៥ និងចំណុចដៅ សំខាន់ៗឆ្នាំ២០១៦ និងបានថ្លែងអំណរគុណ ដល់លេខាធិការដ្ឋានគ.ជ.អ.ប UNDP-EU,FCM, អង្គការខុនរ៉ាដ ដែលបានគាំទ្រ ដល់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ទាំងធនធានថវិកា និងធនធានមនុស្ស។

**លោក គៀង អ៊ាង ប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តក្រចេះ មាន មតិស្វាគមន៍ និងបាន**បានសំដែងគារវៈកិច្ចយ៉ាងកក់ក្តៅចំពោះគណៈអធិបតី ភ្ញៀវកិត្តិយស សមាជិក សមាជិកា ក្រុមប្រឹក្សា និងគណៈកម្មាធិការប្រតិបត្តិជាតិ និងបានកក់សម្គាល់ អំពីសមទ្ធិផលសំខាន់ៗ របស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដែលសម្រេចបានកន្លងមក ។ លោកបានសំដែងការ ស្វាគមន៍ និងជូនពរឱ្យគណៈអធិបតី សមាជិក សមាជិកា ក្នុងអង្គប្រជុំសូមឲ្យដំណើរការស្នាក់នៅលើ ទឹកដីខេត្តក្រចេះប្រកបដោយសេចក្តីសុខសប្បាយនិងទទួលបានជោគជ័យ

## ខ. ការចែករំលែកបទពិសោធន៍

លោក ជ័យ សម្បត្តិផល្លា អនុប្រធានអង្គភាពអភិវឌ្ឍន៍គោលនយោបាយនៃលេខាធិការ ដ្ឋានគ.ជ.អ.បបានធ្វើបទបង្ហាញអំពីវឌ្ឍភាពនៃការអនុវត្ត ផ.អ.៣ ដំណាក់កាលទី២ ឆមាសទី១ ឆ្នាំ ២០១៥ ដោយ លោកបានបង្ហាញអំពីសមិទ្ធិផលរំពឹងទុកទាំង៥ និងសមិទ្ធិផលសម្រេចបានក្នុង ឆមាសទី១ ឆ្នាំ២០១៥ នៅក្នុងសមិទ្ធិផលទាំង៥ ព្រមទាំងបញ្ហាប្រឈម ដូចមានក្នុង***ឧបសម្ព័ន្ធទី ២***

លោក ស៊ុំ សុជាតិ នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន បានបទបង្ហាញ អំពីការប្រែប្រួលអាកាសធាតុ និងឆ្លើយតបមូលដ្ឋាន ការបន្សុំទៅការប្រែប្រួលអាកាសធាតុនៅកម្ពុជា ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងរ៉េដបូក (RED+) ជូនភ្ជាប់ជាមួយ***ឧបសម្ព័ន្ធទី ៣***

## គ. ដំណើរការ កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិ

### គ.១ អំពីរបាយការរីកចំរើន និងផែនការបន្ត

ជាកិច្ចចាប់ផ្តើមកិច្ចប្រជុំ លោក ប៉ុក សុគន្ធដារ៉ា អគ្គលេខាធិការ បានធ្វើបទបង្ហាញអំពី លទ្ធផលសម្រេចបានត្រីមាសទី១ ដល់ត្រីមាសទី៣ ឆ្នាំ២០១៥ និងផែនការឆ្នាំ២០១៦។ បន្ទាប់មក

- ចំពោះប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សាទទួលមរណៈភាព ជាបទពិសោធន៍ខេត្តមួយចំនួនគេបានបង្កើតមូលនិធិមរណៈសង្គ្រោះ ប៉ុន្តែវាជួបការលំបាក និងស្មុគស្មាញខ្លាំងណាស់ដែរ ជាការល្អឯកឧត្តមសុំឲ្យសមាគមថ្នាក់មូលដ្ឋានពិចារណាប្រើប្រាស់ប្រាក់សមាជិកភាពចំពោះកិច្ចការនេះ(២០០០០០រៀល សំរាប់សពមួយ)
- ឯកឧត្តមបានសំដែងការគាំទ្រចំពោះក្តីបារម្ភរបស់លោក លួង ហុន លើសមត្ថភាពមិនសំដៅលើក្រុមប្រឹក្សាឃុំ សង្កាត់ នោះទេ ក្រុមប្រឹក្សាក្រុង ស្រុកក៏ដូចគ្នាផងដែរ យើងនឹងខិតខំប្រឹងប្រែងថែមទៀត។

ចូលរួមបំភ្លឺ លោក ប៉ុក សុគន្ធដារ៉ា បានគូសបញ្ជាក់អំពីការចំណាយកាតទូរស័ព្ទដៃ ការចំណាយនេះមិនមែនជាថវិកាប្រាក់សមាជិកភាពនោះទេ តែវាជាថវិការបស់គម្រោងនានាដូចជាគម្រោង ACES FCM និងIP3 និងបានបញ្ជាក់ពីតួរលេខភាន់ច្រឡំផងដែរ។ រីឯពាក្យថាចំណាយយថាប្រភេទនេះជាកំហុសបច្ចេកទេស ពាក្យត្រឹមត្រូវគឺចំណាយយថាហេតុ។

*បន្ទាប់ពីការពិភាក្សា ឯកឧត្តម សយ កុសល បានស្នើសុំសមាជិក សមាជិការក្រុមប្រឹក្សាជាតិធ្វើការអនុម័តរបាយការណ៍រីកចំរើន និងរបាការណ៍ហិរញ្ញវត្ថុ ឆ្នាំ២០១៥ និងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ សមាជិកា សមាជិកានូវសម្លេងលើសលប់ជាឯកច្ឆ័ន្ទ។*

## គ.២ អំពីគោលនយោបាយគ្រប់គ្រង និងប្រតិបត្តិការ

មុនពេលចាប់ផ្តើមលោក អេនតូនីញ៉ូ (UNDP) បានចូលរួមចំណាប់អារម្មណ៍ លោកបានជំរាបជូនថាគម្រោងត្រូវបានបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥នេះ។ មន្ត្រី និងទីប្រឹក្សាគម្រោងបាននឹងកំពុងរៀបចំឯកសារពន្យាគម្រោងដែលនឹងត្រូវដាក់ឲ្យគណកម្មការគ្រប់គ្រងគម្រោងប្រជុំពិនិត្យ និងអនុ័តនៅក្នុងខែវិច្ឆិកានេះ។ លោកសូមឲ្យអង្គប្រជុំនេះផ្តោតការយកចិត្តទុកដាក់ពិនិត្យ និងអនុម័តឯកសារគោលនយោបាយគ្រប់គ្រង និងប្រតិបត្តិការ ព្រោះវាជាឧបករណ៍ដ៏សំខាន់សម្រាប់សមាគមក្នុងការអនុវត្តអាណត្តិ និងថវិការបស់ខ្លួន។

លោក ស៊ាង រ៉ូស្សាត អគ្គលេខាធិការរង បានធ្វើបទបង្ហាញអំពីគោលនយោបាយគ្រប់គ្រង និងប្រតិបត្តិការខ្លឹមសាររួមដូចមាននៅក្នុង***ឧបសម្ព័ន្ធទី ៧***។

បន្ទាប់មក ឯកឧត្តម សយ កុសល បានដឹកនាំការពិភាក្សាដូចខាងខាងក្រោម៖

លោកស្រី គា ថាវី លើកឡើងពីជំពូកទី៥ ទាក់ទងចំណុចឈប់សម្រាកមរណៈទុក្ខ សូមពន្យល់ឲ្យច្បាស់បន្តិច។ និងចំណុចការសម្រាកបិតុភាព។

លោក ប៉ុក សុគន្ធដារ៉ា បានបកស្រាយលើចំណុច ការប្រើប្រាស់ស្របច្បាប់ គឺនិយាយសំដៅលើ ការប្រើប្រាស់កុំព្យូទ័រ គឺមានន័យថាកុំព្យូទ័រអគ្គលេខាធិការដ្ឋាន ត្រូវអនុវត្តទៅតាមលិខិតបទដ្ឋាន និងគោលការណ៍របស់ក្រសួង ស្ថាប័នបានណែនាំ។ រីឯ ការប្រើប្រាស់សមស្រប និងមិនសមស្រប គឺសំដៅទៅការប្រើប្រាស់កុំព្យូទ័រ ដោយមានការថែរក្សាមិនឲ្យខូចខាត ឬមិនប្រើប្រាស់ទៅលើអ្វីដែលត្រូវបានហាមឃាត់ដោយអគ្គលេខាធិការដ្ឋាន។ ចំណែកឯ ការផលប្រយោជន៍ផ្ទាល់ខ្លួន គឺចំណុចនេះផ្អែកទៅលើ លក្ខន្តិកៈរបស់សម្ព័ន្ធភាពជាតិ មានន័យថាក្នុងតួនាទីភារកិច្ច របស់ក្រុមប្រឹក្សាតំណាងប្រយោជន៍សាធារណៈ មិនអាចគិតពីប្រយោជន៍ផ្ទាល់ខ្លួននោះទេ។ ចំពោះពាក់ព័ន្ធ និងឈប់សម្រាកមរណៈទុក្ខ គឺសង្កត់ធ្ងន់ ទៅលើសាច់ញាតិរបស់បុគ្គលិក ដែលទទួលបានមរណៈ គឺទទួលបានឈប់សម្រាកដូចបានកំណត់ក្នុងឯកសារបច្ចេកទេសនេះ ហើយនូវទទួលប្រាក់ខែធម្មតា។ ចំណុចសម្រាកបិតុភាព គឺសំដៅទៅពេលប្រពន្ធរបស់បុគ្គលិកដែលសម្រាលកូន នោះប្ដីអាចមានសិទ្ធិឈប់សម្រាកដូចមានកំណត់ក្នុងឯកសារនេះ។

លោក កាន់ វណ្ណា មានសំណូមពរឯកសារគោលនយោបាយគ្រប់គ្រង និងប្រតិបត្តិការ

លោក យស់ យឿន បានសំណូមពរបកស្រាយបន្ថែមលើប្រាក់ឧបត្ថម្ភបេសកកម្ម និងថ្លៃធ្វើដំណើរ ឲ្យបានច្បាស់។ ហើយការងារនេះគ្របដណ្តប់ទៅលើសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានដែររឺទេ?

លោក ប៉ុក សុគន្ធដារ៉ា បានបកស្រាយថា ឯកសារបច្ចេកទេសនេះគឺប្រើប្រាស់សម្រាប់អនុវត្តនៅក្នុងអគ្គលេខាធិការដ្ឋាន ប៉ុន្តែបើសមាគមក្រុមប្រឹក្សាមូលដ្ឋានចង់អនុវត្តអាចយកឯកសារនេះ យកទៅកែសម្រួលបន្ថែម រួចហើយដាក់អនុម័តដោយក្រុមប្រឹក្សារបស់សមាគមក្រុមប្រឹក្សាមូលដ្ឋានរបស់ខ្លួនមុន នឹងប្រើប្រាស់។

**ឯកឧត្តម សយ កុសល** បានប្រសាសន៍បន្ថែមថា លើឯកសារគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ ឬ គ.ជ.អ.ប គឺប្រើប្រាស់សម្រាប់មន្ត្រីរដ្ឋាភិបាល និងមន្ត្រីគម្រោងរបស់ ផអព ត្រូវចាំថា នេះជាគោលការណ៍ដាច់ដោយឡែក។ រីឯសមាគមត្រូវប្រើប្រាស់តាមយន្តការរបស់ខ្លួន ព្រោះសម្ព័ន្ធភាពជាតិ និងសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន គឺមានថវិកានូវខ្សត់ខ្សោយ។

មធ្យមមាន ១៨ នាក់ ស្មើនឹង ២៣,៦៩% អ្នកផ្តល់ពិន្ទុល្អ មាន ៥៨ នាក់ ស្មើនឹង ៧៦,៣១%។ លទ្ធផលនៃការវាយតម្លៃមានភ្ជាប់ជា***ឧបសម្ព័ន្ធទី ៩***។

**ឃ. កម្មវិធីបិទ**

ក្នុងមតិផ្តាំផ្ញើ និងបិទកិច្ចប្រជុំ **ឯកឧត្តម សយ** កុសល ក្នុងនាមប្រធានអង្គប្រជុំ បានថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងសមាជិក សមាជិកាគណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិ និងភ្ញៀវកិត្តិយស ទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងកិច្ចប្រជុំនេះ។ ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះឯកឧត្តមបានផ្តល់នូវអនុសាសន៍មួយចំនួន ១) សូមឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ដូចគ្នាផងដែរលើកយកចិត្តទុកដាក់កំពស់ការអនុវត្តថវិកា និងគម្រោង ២) សូមឲ្យមានការផ្សព្វផ្សាយអំពីការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដល់សមាជិកក្រុមប្រឹក្សាទាំងអស់ ៣) សូមឲ្យមានការចែករំលែកព័ត៌មាន និងបទពិសោធន៍ពីគ្នាទៅវិញទៅមក ៤) លើកកំពស់ការអនុវត្តក្រមសីលធម៌ និង៥) លើកកំពស់ការប្រើប្រាស់ឯកសណ្ឋាន និងសញ្ញាស័ក្តិ

កិច្ចប្រជុំ បានចប់សព្វគ្រប់នៅវេលាម៉ោង ១២ និង ១៥ នាទី នាថ្ងៃខែឆ្នាំដដែល ប្រកបដោយភាពស្និទ្ធស្នាល និងរីករាយក្រៃលែង។

ក្រចេះ ថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០១៥

អ្នករៀបចំកំណត់ហេតុ

**វ៉ាន់ ថេន**

**បានឃើញ និងឯកភាព**

**ប្រធានអង្គប្រជុំ**

**សយ កុសល**

## ការគណនាប្រាក់សមាជិកភាពសម្ព័ន្ធភាពជាតិ និងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឆ្នាំ ២០១៦

| ល.រ | រាជធានី ខេត្ត | ប្រាក់រដ្ឋបាល-បន្ទុកបុគ្គលិកឃុំ សង្កាត់ | ប្រាក់រដ្ឋបាល-បន្ទុកបុគ្គលិក ក្រុង ស្រុក | 2.5%នៃប្រាក់រដ្ឋបាល-បន្ទុកបុគ្គលិក ឃុំ សង្កាត់ | 3.5% នៃប្រាក់រដ្ឋបាល-បន្ទុកបុគ្គលិក ក្រុង ស្រុក | សរុប 2.5% និង 3.5% នៃប្រាក់រដ្ឋបាល-បន្ទុកបុគ្គលិក | | ផ្ទេរមកសម្ព័ន្ធ ២០% | | នៅសមាគម ៨០% | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ជារៀល | ជាដុល្លា | ជារៀល | ជាដុល្លា | ជារៀល | ជាដុល្លា |
| 1 | បន្ទាយមានជ័យ | 1,174,380,000 | 451,390,000 | 29,359,500 | 15,798,650 | 45,158,150 | 11,289.54 | 9,031,630 | 2,257.91 | 36,126,520 | 9,031.63 |
| 2 | បាត់ដំបង | 1,852,960,000 | 670,900,000 | 46,324,000 | 23,481,500 | 69,805,500 | 17,451.38 | 13,961,100 | 3,490.28 | 55,844,400 | 13,961.10 |
| 3 | កំពង់ចាម | 1,900,760,000 | 525,800,000 | 47,519,000 | 18,403,000 | 65,922,000 | 16,480.50 | 13,184,400 | 3,296.10 | 52,737,600 | 13,184.40 |
| 4 | កំពង់ឆ្នាំង | 1,068,430,000 | 408,440,000 | 26,710,750 | 14,295,400 | 41,006,150 | 10,251.54 | 8,201,230 | 2,050.31 | 32,804,920 | 8,201.23 |
| 5 | កំពង់ស្ពឺ | 1,456,450,000 | 425,580,000 | 36,411,250 | 14,895,300 | 51,306,550 | 12,826.64 | 10,261,310 | 2,565.33 | 41,045,240 | 10,261.31 |
| 6 | កំពង់ធំ | 1,377,500,000 | 411,950,000 | 34,437,500 | 14,418,250 | 48,855,750 | 12,213.94 | 9,771,150 | 2,442.79 | 39,084,600 | 9,771.15 |
| 7 | កំពត | 1,430,720,000 | 449,310,000 | 35,768,000 | 15,725,850 | 51,493,850 | 12,873.46 | 10,298,770 | 2,574.69 | 41,195,080 | 10,298.77 |
| 8 | កណ្ដាល | 2,152,140,000 | 587,920,000 | 53,803,500 | 20,577,200 | 74,380,700 | 18,595.18 | 14,876,140 | 3,719.04 | 59,504,560 | 14,876.14 |
| 9 | កោះកុង | 434,670,000 | 290,530,000 | 10,866,750 | 10,168,550 | 21,035,300 | 5,258.83 | 4,207,060 | 1,051.77 | 16,828,240 | 4,207.06 |
| 10 | ក្រចេះ | 717,490,000 | 295,670,000 | 17,937,250 | 10,348,450 | 28,285,700 | 7,071.43 | 5,657,140 | 1,414.29 | 22,628,560 | 5,657.14 |
| 11 | មណ្ឌលគិរី | 296,660,000 | 210,390,000 | 7,416,500 | 7,363,650 | 14,780,150 | 3,695.04 | 2,956,030 | 739.01 | 11,824,120 | 2,956.03 |
| 12 | ភ្នំពេញ | 1,783,860,000 | - | 44,596,500 | - | 44,596,500 | 11,149.13 | 8,919,300 | 2,229.83 | 35,677,200 | 8,919.30 |
| 13 | ព្រះវិហារ | 828,980,000 | 356,380,000 | 20,724,500 | 12,473,300 | 33,197,800 | 8,299.45 | 6,639,560 | 1,659.89 | 26,558,240 | 6,639.56 |
| 14 | ព្រៃវែង | 2,050,930,000 | 667,110,000 | 51,273,250 | 23,348,850 | 74,622,100 | 18,655.53 | 14,924,420 | 3,731.11 | 59,697,680 | 14,924.42 |
| 15 | ពោធិ៍សាត់ | 823,040,000 | 298,470,000 | 20,576,000 | 10,446,450 | 31,022,450 | 7,755.61 | 6,204,490 | 1,551.12 | 24,817,960 | 6,204.49 |
| 16 | រតនគិរី | 713,280,000 | 385,070,000 | 17,832,000 | 13,477,450 | 31,309,450 | 7,827.36 | 6,261,890 | 1,565.47 | 25,047,560 | 6,261.89 |
| 17 | សៀមរាប | 1,633,380,000 | 609,800,000 | 40,834,500 | 21,343,000 | 62,177,500 | 15,544.38 | 12,435,500 | 3,108.88 | 49,742,000 | 12,435.50 |
| 18 | ព្រះសីហនុ | 421,450,000 | 184,170,000 | 10,536,250 | 6,445,950 | 16,982,200 | 4,245.55 | 3,396,440 | 849.11 | 13,585,760 | 3,396.44 |
| 19 | ស្ទឹងត្រែង | 483,990,000 | 230,450,000 | 12,099,750 | 8,065,750 | 20,165,500 | 5,041.38 | 4,033,100 | 1,008.28 | 16,132,400 | 4,033.10 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| 20 | ស្វាយរៀង | 1,271,470,000 | 406,420,000 | 31,786,750 | 14,224,700 | 46,011,450 | 11,502.86 | 9,202,290 | 2,300.57 | 36,809,160 | 9,202.29 |
| 21 | តាកែវ | 1,721,890,000 | 525,530,000 | 43,047,250 | 18,393,550 | 61,440,800 | 15,360.20 | 12,288,160 | 3,072.04 | 49,152,640 | 12,288.16 |
| 22 | ឧត្តរមានជ័យ | 381,330,000 | 234,590,000 | 9,533,250 | 8,210,650 | 17,743,900 | 4,435.98 | 3,548,780 | 887.20 | 14,195,120 | 3,548.78 |
| 23 | កែប | 78,460,000 | 84,490,000 | 1,961,500 | 2,957,150 | 4,918,650 | 1,229.66 | 983,730 | 245.93 | 3,934,920 | 983.73 |
| 24 | ប៉ៃលិន | 127,910,000 | 94,020,000 | 3,197,750 | 3,290,700 | 6,488,450 | 1,622.11 | 1,297,690 | 324.42 | 5,190,760 | 1,297.69 |
| 25 | ត្បូងឃ្មុំ | 1,192,870,000 | 363,590,000 | 29,821,750 | 12,725,650 | 42,547,400 | 10,636.85 | 8,509,480 | 2,127.37 | 34,037,920 | 8,509.48 |
| | | 27,375,000,000 | 9,167,970,000 | 684,375,000 | 320,878,950 | 1,005,253,950 | 251,313 | 201,050,790 | 50,263 | 804,203,160 | 201,051 |

## ការគណនាប្រាក់សមាជិកភាពសម្ព័ន្ធភាពជាតិ និងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឆ្នាំ ២០១៦

| ល.រ | រាជធានី ខេត្ត | ប្រាក់រដ្ឋបាល-បន្ទុកបុគ្គលិកឃុំ សង្កាត់ | ប្រាក់រដ្ឋបាល-បន្ទុកបុគ្គលិក ក្រុង ស្រុក | ២%នៃប្រាក់រដ្ឋបាល-បន្ទុក បុគ្គលិកឃុំ សង្កាត់ | ៣% នៃប្រាក់រដ្ឋបាល-បន្ទុក បុគ្គលិកក្រុង ស្រុក | សរុប 2% និង 3% នៃប្រាក់រដ្ឋាបាល-បន្ទុកបុគ្គលិក | | ផ្ទេរមកសម្ព័ន្ធ ២០% | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | ជារៀល | ជាដុល្លា | ជារៀល | ជាដុល្លា |
| 1 | បន្ទាយមានជ័យ | 1,174,380,000 | 451,390,000 | 23,487,600 | 13,541,700 | 37,029,300 | 9,257.33 | 7,405,860 | 1,851.47 |
| 2 | បាត់ដំបង | 1,852,960,000 | 670,900,000 | 37,059,200 | 402,540 | 37,461,740 | 9,365.44 | 7,492,348 | 1,873.09 |
| 3 | កំពង់ចាម | 1,900,760,000 | 525,800,000 | 38,015,200 | 315,480 | 38,330,680 | 9,582.67 | 7,666,136 | 1,916.53 |
| 4 | កំពង់ឆ្នាំង | 1,068,430,000 | 408,440,000 | 21,368,600 | 245,064 | 21,613,664 | 5,403.42 | 4,322,733 | 1,080.68 |
| 5 | កំពង់ស្ពឺ | 1,456,450,000 | 425,580,000 | 29,129,000 | 255,348 | 29,384,348 | 7,346.09 | 5,876,870 | 1,469.22 |
| 6 | កំពង់ធំ | 1,377,500,000 | 411,950,000 | 27,550,000 | 247,170 | 27,797,170 | 6,949.29 | 5,559,434 | 1,389.86 |
| 7 | កំពត | 1,430,720,000 | 449,310,000 | 28,614,400 | 269,586 | 28,883,986 | 7,221.00 | 5,776,797 | 1,444.20 |
| 8 | កណ្ដាល | 2,152,140,000 | 587,920,000 | 43,042,800 | 352,752 | 43,395,552 | 10,848.89 | 8,679,110 | 2,169.78 |
| 9 | កោះកុង | 434,670,000 | 290,530,000 | 8,693,400 | 174,318 | 8,867,718 | 2,216.93 | 1,773,544 | 443.39 |
| 10 | ក្រចេះ | 717,490,000 | 295,670,000 | 14,349,800 | 177,402 | 14,527,202 | 3,631.80 | 2,905,440 | 726.36 |
| 11 | មណ្ឌលគិរី | 296,660,000 | 210,390,000 | 5,933,200 | 126,234 | 6,059,434 | 1,514.86 | 1,211,887 | 302.97 |
| 12 | ភ្នំពេញ | 1,783,860,000 | - | 35,677,200 | - | 35,677,200 | 8,919.30 | 7,135,440 | 1,783.86 |
| 13 | ព្រះវិហារ | 828,980,000 | 356,380,000 | 16,579,600 | 213,828 | 16,793,428 | 4,198.36 | 3,358,686 | 839.67 |
| 14 | ព្រៃវែង | 2,050,930,000 | 667,110,000 | 41,018,600 | 400,266 | 41,418,866 | 10,354.72 | 8,283,773 | 2,070.94 |
| 15 | ពោធិ៍សាត់ | 823,040,000 | 298,470,000 | 16,460,800 | 179,082 | 16,639,882 | 4,159.97 | 3,327,976 | 831.99 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 16 | រតនគិរី | 713,280,000 | 385,070,000 | 14,265,600 | 231,042 | 14,496,642 | 3,624.16 | 2,899,328 | 724.83 |
| 17 | សៀមរាប | 1,633,380,000 | 609,800,000 | 32,667,600 | 365,880 | 33,033,480 | 8,258.37 | 6,606,696 | 1,651.67 |
| 18 | ព្រះសីហនុ | 421,450,000 | 184,170,000 | 8,429,000 | 110,502 | 8,539,502 | 2,134.88 | 1,707,900 | 426.98 |
| 19 | ស្ទឹងត្រែង | 483,990,000 | 230,450,000 | 9,679,800 | 138,270 | 9,818,070 | 2,454.52 | 1,963,614 | 490.90 |
| 20 | ស្វាយរៀង | 1,271,470,000 | 406,420,000 | 25,429,400 | 243,852 | 25,673,252 | 6,418.31 | 5,134,650 | 1,283.66 |
| 21 | តាកែវ | 1,721,890,000 | 525,530,000 | 34,437,800 | 315,318 | 34,753,118 | 8,688.28 | 6,950,624 | 1,737.66 |
| 22 | ឧត្តរមានជ័យ | 381,330,000 | 234,590,000 | 7,626,600 | 140,754 | 7,767,354 | 1,941.84 | 1,553,471 | 388.37 |
| 23 | កែប | 78,460,000 | 84,490,000 | 1,569,200 | 50,694 | 1,619,894 | 404.97 | 323,979 | 80.99 |
| 24 | ប៉ៃលិន | 127,910,000 | 94,020,000 | 2,558,200 | 56,412 | 2,614,612 | 653.65 | 522,922 | 130.73 |
| 25 | ត្បូងឃ្មុំ | 1,192,870,000 | 363,590,000 | 23,857,400 | 218,154 | 24,075,554 | 6,018.89 | 4,815,111 | 1,203.78 |
| | | 27,375,000,000 | 9,167,970,000 | 547,500,000.00 | 18,771,648 | 566,271,648 | 141,568 | 113,254,330 | 28,314 |

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ២០១៧ អនក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៤

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ជម្រាបមក**

**លោក សយ កុសល ប្រធានសម្ព័ន្ធភាពជាតិ**
**ឃុំ សង្កាត់នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ** : ស្តីពីការស្នើសុំទទួលស្គាល់ប្រធាន និងសមាសភាពថ្មី នៃរចនាសម្ព័ន្ធ ព្រមទាំងធ្វើវិសោធនកម្មលក្ខន្តិកៈ និងប្តូរឈ្មោះពីសម្ព័ន្ធភាពជាតិឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ទៅជាសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ។

**យោង** : -លិខិតលេខ ១១៥៦ សជណ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ ។
-លិខិតលេខ ០៨៩/១៤ ល.ស ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ របស់លោក សយ កុសល ប្រធានសម្ព័ន្ធភាពជាតិឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ។

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជម្រាបលោកប្រធានថា ក្រសួងមហាផ្ទៃបានឯកភាព លើការស្នើសុំទទួលស្គាល់លោក សយ កុសលជាប្រធាន និងសមាសភាពថ្មី នៃរចនាសម្ព័ន្ធ ព្រមទាំងធ្វើវិសោធនកម្មលក្ខន្តិកៈ និងប្តូរឈ្មោះពី **សម្ព័ន្ធភាពជាតិឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា** ទៅជា**សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា** នោះហើយ ។ សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលនៅក្នុងបរិវេណ ព្រឹទ្ធសភា មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រូវអនុវត្តតាមលក្ខន្តិកៈ ដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសម្ព័ន្ធភាពជាតិសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យ គណបក្សនយោបាយ មិនធ្វើជាឧបករណ៍គណបក្សនយោបាយ និងមិនស្វែងរកប្រាក់កម្រៃជាឯកជន ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីឱ្យបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាប និងចាត់វិធានការអនុវត្តតាមការគួរ ។

សូមលោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ឧ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ប៉ុល លឹម

*ចម្លងជូន:*
- ទីស្តីការគណៈរដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ